# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ.....០៤០.....ប្រក.កសក

## ប្រកាស

## ស្តីពី

## នីតិវិធីនៃការស្នើសុំបង្កើត
## និងដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា ២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បកចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា ២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ១០ សរណន ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីវិធានការទប់ស្កាត់ការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស
- បានឃើញប្រកាសលេខ១៣៨ ប្រក កសក ប ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន និងវិទ្យាស្ថាន នៃអគ្គនាយដ្ឋានកៅស៊ូ
- បានឃើញប្រកាសលេខ១៨០ ប្រក កសក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការគ្រប់គ្រងស្ថាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១ .—**

ប្រកាសនេះ មានគោលបំណងកំណត់នីតិវិធី ក្នុងការស្នើសុំលិខិតអនុញ្ញាតបង្កើតនិងវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ សំដៅលើកកម្ពស់គុណភាពកៅស៊ូ និងឈើកៅស៊ូ។

**ប្រការ២ .—**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការបង្កើតនិងដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ។

**ប្រការ៣ .—**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **កៅស៊ូ** សំដៅដល់កៅស៊ូធម្មជាតិដែលជាសារធាតុផលិតចេញពីរុក្ខជាតិពួក (Genus) *Hevea*
- **កែច្នៃកៅស៊ូ** សំដៅដល់ការកែច្នៃកៅស៊ូបឋមពីទឹកជ័រនិងជ័រកកដូចជា៖ កៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: Technically Specified Rubber) ទឹកជ័រខាប់ (Concentrated Latex) កៅស៊ូក្រេប (Crepe Rubber) កៅស៊ូសមាស (Compound Rubber) កៅស៊ូចម្រុះ (Mixed Rubber) កៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: Ribbed Smoked Sheet) និងកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: Air Dried Sheet)
- **កែច្នៃឈើកៅស៊ូ** សំដៅដល់ការកែច្នៃបឋមពីឈើកៅស៊ូតាមរយៈការអារ ច្រៀក ក្រោះផ្ទាំ សម្ងួត និងឈូសមុខពីរ (S2S: Surfaced two Sides) ឈូសមុខបួន (S4S: Surfaced four Sides) [illegible] (Veneer) ក្ដារកៀប និងក្ដារបន្ទះ (Plywood)
- **ឈើកៅស៊ូ** សំដៅដល់ឈើដែលទទួលបានពីដើមកៅស៊ូចាប់ពីមិនទាន់កែច្នៃរហូតដល់កែច្នៃបឋម

- **រោងចក្រកែច្នៃកៅស៊ូ** សំដៅដល់ទីកន្លែងដែលមានអគារបំពាក់ដោយខ្សែបច្ចេកវិទ្យា (ឧបករណ៍ ម៉ាស៊ីន សម្ភារ និងបរិក្ខារ) ដើម្បីកែច្នៃកៅស៊ូ ដែលមានទុនសមមូលសរុបចាប់ពី ៥០០ ០០០ (ប្រាំរយពាន់) ដុល្លារសហរដ្ឋអាមេរិកឡើងទៅ
- **រោងចក្រកែច្នៃឈើកៅស៊ូ** សំដៅដល់ទីកន្លែងដែលមានអគារបំពាក់ដោយខ្សែបច្ចេកវិទ្យា (ឧបករណ៍ ម៉ាស៊ីន សម្ភារ និងបរិក្ខារ) ដើម្បីកែច្នៃឈើកៅស៊ូ ដែលមានទុនសមមូលសរុបចាប់ពី ២៥០ ០០០ (ពីររយហាសិបពាន់) ដុល្លារសហរដ្ឋអាមេរិកឡើងទៅ
- **សិប្បកម្មកែច្នៃកៅស៊ូ** សំដៅដល់ទីកន្លែងដែលមានអគារបំពាក់ដោយខ្សែបច្ចេកវិទ្យា (ឧបករណ៍ ម៉ាស៊ីន សម្ភារ និងបរិក្ខារ) ដើម្បីកែច្នៃកៅស៊ូ ដែលមានទុនសមមូលសរុបតិចជាង ៥០០ ០០០ (ប្រាំរយពាន់) ដុល្លារសហរដ្ឋអាមេរិក
- **សិប្បកម្មកែច្នៃឈើកៅស៊ូ** សំដៅដល់ទីកន្លែងដែលមានអគារបំពាក់ដោយខ្សែបច្ចេកវិទ្យា (ឧបករណ៍ ម៉ាស៊ីន សម្ភារ និងបរិក្ខារ) ដើម្បីកែច្នៃឈើកៅស៊ូ ដែលមានទុនសមមូលសរុបតិចជាង ២៥០ ០០០ (ពីររយហាសិបពាន់) ដុល្លារសហរដ្ឋអាមេរិក។

## ជំពូកទី២
## ការចេញលិខិតអនុញ្ញាត
## បង្កើតរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ

### ផ្នែកទី១
### ការចេញលិខិតអនុញ្ញាតបង្កើតរោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូ

**ប្រការ៤ .—**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងបង្កើតរោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ត្រូវមានឯកសារតម្រូវដូចខាងក្រោម៖

១- ពាក្យស្នើសុំអនុញ្ញាតបង្កើតរោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូ (មានគំរូ)។
២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន។
៣- ប្រវត្តិរូបសង្ខេបរបស់ម្ចាស់រោងចក្រមានបិទរូបថត ៤X៦ មានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន។
៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លក្ខន្តិកៈក្រុមហ៊ុន និងប័ណ្ណប៉ាតង់។
៥- របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព។
៦- គំនូសបង្ហាញទីតាំង ប្លង់រួម ប្លង់អគារ និងគំនូសបំព្រួញខ្សែច្រវាក់ផលិតកម្ម។
៧- របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមចេញដោយអាជ្ញាធរមានសមត្ថកិច្ច (មានគំរូ)។
៨- កិច្ចសន្យាជួលទីតាំង ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនទ្រព្យ ទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៥ .—**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតបង្កើតរោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូ៖
- ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបង្កើត នៅអគ្គនាយកដ្ឋានកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ត្រូវបំពេញពាក្យស្នើសុំ និងភ្ជាប់ជាមួយនូវសំណុំឯកសារឱ្យបានត្រឹមត្រូវ និងពេញលេញ តាមទម្រង់ដែលមាននៅក្នុងគំរូសំណុំបែបបទដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ៦ .—**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលសុំលិខិតអនុញ្ញាតបង្កើតរោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូ អាចទទួលលទ្ធផលនៃការសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើពាក្យស្នើសុំរបស់ខ្លួនក្នុងរយៈពេលមិនលើសពី ៤៥ (សែសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលសំណុំឯកសារពាក្យស្នើសុំគ្រប់គ្រាន់ និងពេញលេញ នៅអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លិខិតអនុញ្ញាតបង្កើតរោងចក្រកែច្នៃកៅស៊ូ និងឈើកៅស៊ូមានសុពលភាពអចិន្ត្រៃយ៍ លើកលែងតែមានការព្យួរ ឬការដកហូតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងករណីអនុវត្តខុសនឹងបញ្ញត្តិមានចែងក្នុងប្រកាសនេះ។

**ប្រការ៧ .—**

រាល់ការប្តូរទីតាំង ពង្រីក ឬបង្កើតសាខារោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ត្រូវស្នើសុំលិខិតអនុញ្ញាតជាថ្មីពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៨ .—**

សិទ្ធិវន្តដែលបានទទួលការកាន់កាប់រោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូបន្ត ត្រូវជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃដែលខ្លួនទទួលសិទ្ធិជាម្ចាស់ថ្មី និងត្រូវមានកាតព្វកិច្ចដូចគ្នា ក្នុងការអនុវត្តតាមនីតិវិធីនៃប្រកាសនេះ។

**ប្រការ៩ .—**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កើតរោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូត្រូវអនុវត្តលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

- ត្រូវមាននិយោជិតបច្ចេកទេសទទួលខុសត្រូវដែលមានសញ្ញាបត្រជំនាញកៅស៊ូ កសិក្រសាស្ត្រ ឬជំនាញពាក់ព័ន្ធយ៉ាងទាបបំផុតត្រឹមបរិញ្ញាបត្រ
- ត្រូវរក្សាសុវត្ថិភាពការងារដល់កម្មករ និងនិយោជិតអនុលោមតាមច្បាប់ការងារ
- មិនត្រូវបង្កហានិភ័យ ឬការខូចខាតដល់បរិស្ថាន និងសង្គមជាតិ
- ត្រូវដាក់តាំងលិខិតអនុញ្ញាតបង្កើតរោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូ នៅក្នុងរោងចក្ររបស់ខ្លួន
- ត្រូវអនុញ្ញាតឱ្យមន្ត្រីបច្ចេកទេសមានសមត្ថកិច្ចពីអគ្គនាយកដ្ឋានកៅស៊ូ ចុះត្រួតពិនិត្យ និងវាយតម្លៃលើប្រតិបត្តិការបច្ចេកទេសរបស់រោងចក្រកែច្នៃកៅស៊ូ និងឈើកៅស៊ូ
- ត្រូវចូលរួម និងសហការជាមួយអគ្គនាយកដ្ឋានកៅស៊ូ ក្នុងការស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេស
- ត្រូវផ្តល់របាយការណ៍ និងទិន្នន័យពាក់ព័ន្ធប្រចាំខែមកអគ្គនាយកដ្ឋានកៅស៊ូ ជាចាំបាច់
- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកដំណើរការរោងចក្រកែច្នៃកៅស៊ូ ឬឈើកៅស៊ូជាស្ថាពរមកអគ្គនាយកដ្ឋានកៅស៊ូ
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀត ដែលតម្រូវដោយអគ្គនាយកដ្ឋានកៅស៊ូ។

## ផ្នែកទី២
## ការចេញលិខិតអនុញ្ញាតបង្កើតសិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ

**ប្រការ១០ .–**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងបង្កើតសិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ត្រូវមានឯកសារតម្រូវដូចខាងក្រោម៖

១- ពាក្យស្នើសុំលិខិតអនុញ្ញាតបង្កើតសិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ (មានគំរូ)។

២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន។

៣- ប្រវត្តិរូបសង្ខេបរបស់ម្ចាស់សិប្បកម្មមានបិទរូបថត ៤x៦ មានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង/ឬលក្ខន្តិកៈក្រុមហ៊ុន និងប័ណ្ណប៉ាតង់។

៥- របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព។

៦- គំនូសបង្ហាញទីតាំង ប្លង់រួម ប្លង់អគារ និងគំនូសបំព្រួញខ្សែច្រវាក់ផលិតកម្ម។

៧- របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមចេញដោយអាជ្ញាធរមានសមត្ថកិច្ច (មានគំរូ)។

៨- កិច្ចសន្យាជួលទីតាំង ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនទ្រព្យ ទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ១១ .–**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតបង្កើតសិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ៖

- ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបង្កើត នៅអគ្គនាយកដ្ឋានកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ត្រូវបំពេញសំណុំឯកសារឱ្យបានត្រឹមត្រូវ និងពេញលេញ តាមការកំណត់នៅក្នុងគំរូសំណុំបែបបទដូចមានក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

**ប្រការ១២ .–**

អគ្គនាយកដ្ឋានកៅស៊ូ ត្រូវធ្វើការពិនិត្យ និងវាយតម្លៃលើពាក្យស្នើសុំ។ បើពិនិត្យឃើញថាសំណុំឯកសារនោះពិតជាត្រឹមត្រូវ និងពេញលេញស្របតាមនីតិវិធី អគ្គនាយកដ្ឋានកៅស៊ូ ត្រូវសុំគោលការណ៍សម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ផ្អែកតាមគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកៅស៊ូ ត្រូវចេញលិខិតអនុញ្ញាតជូនអ្នកស្នើសុំ។

ដំណើរការពិនិត្យ និងសម្រេចលើពាក្យស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល មានរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំគ្រប់គ្រាន់ និងត្រឹមត្រូវ។

លិខិតអនុញ្ញាតបង្កើតសិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ មានសុពលភាពអចិន្ត្រៃយ៍ លើកលែងតែមានការព្យួរ ឬការដកហូតដោយអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងករណីអនុវត្តខុសនឹងបញ្ញត្តិមានចែងក្នុងប្រកាសនេះ។

**ប្រការ១៣ .–**

រាល់ការប្ដូរទីតាំង ពង្រីក ឬបង្កើតសាខាសិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ត្រូវស្នើសុំលិខិតអនុញ្ញាតជាថ្មីពីអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ១៤ .—**

សិទ្ធិវន្តដែលបានទទួលការកាន់កាប់សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូបន្ត ត្រូវជូនដំណឹងមកអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃដែលខ្លួនទទួលសិទ្ធិជាម្ចាស់ថ្មី និងត្រូវមានកាតព្វកិច្ចដូចគ្នា ក្នុងការអនុវត្តតាមនីតិវិធីនៃប្រកាសនេះ។

**ប្រការ១៥ .—**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កើតសិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ត្រូវអនុវត្តលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

- ត្រូវមាននិយោជិតបច្ចេកទេសទទួលខុសត្រូវដែលមានសញ្ញាបត្រជំនាញកៅស៊ូ ក្សេត្រសាស្ត្រ ឬជំនាញពាក់ព័ន្ធយ៉ាងទាបបំផុតត្រឹមបរិញ្ញាបត្ររង
- ត្រូវរក្សាសុវត្ថិភាពការងារដល់កម្មករ និងនិយោជិតអនុលោមតាមច្បាប់ការងារ
- មិនត្រូវបង្កហានិភ័យ ឬការខូចខាតដល់បរិស្ថាន និងសង្គមជាតិ
- ត្រូវដាក់តាំងលិខិតអនុញ្ញាតបង្កើតសិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ នៅក្នុងសិប្បកម្មរបស់ខ្លួន
- ត្រូវអនុញ្ញាតឱ្យមន្ត្រីបច្ចេកទេសមានសមត្ថកិច្ចពីអគ្គនាយកដ្ឋានកៅស៊ូ ចុះត្រួតពិនិត្យ និងវាយតម្លៃលើប្រតិបត្តិការបច្ចេកទេសរបស់សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ
- ត្រូវចូលរួម និងសហការជាមួយអគ្គនាយកដ្ឋានកៅស៊ូ ក្នុងការស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេស
- ត្រូវផ្តល់របាយការណ៍ និងទិន្នន័យពាក់ព័ន្ធប្រចាំខែមកអគ្គនាយកដ្ឋានកៅស៊ូ ជាចាំបាច់
- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងតិច មុនថ្ងៃឈប់ដំណើរការសិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូជាស្ថាពរមកអគ្គនាយកដ្ឋានកៅស៊ូ
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀត ដែលតម្រូវដោយអគ្គនាយកដ្ឋានកៅស៊ូ។

## ជំពូកទី៣
## ការចេញវិញ្ញាបនបត្រអនុញ្ញាត
## ដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ

**ប្រការ១៦ .—**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលលិខិតអនុញ្ញាតបង្កើតរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ត្រូវមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការនៅអគ្គនាយកដ្ឋានកៅស៊ូ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនការបើកដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ជាផ្លូវការ។

**ប្រការ១៧ .—**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ត្រូវបំពេញសំណុំឯកសារឱ្យបានត្រឹមត្រូវ និងពេញលេញតាមការកំណត់នៅក្នុងគំរូសំណុំបែបបទដូចមានក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ អាចទទួលលទ្ធផលនៃការសម្រេចពីអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើពាក្យស្នើសុំរបស់ខ្លួនក្នុងរយៈពេលមិនលើសពី១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលបានឯកសារពាក្យស្នើសុំត្រឹមត្រូវ និងពេញលេញនៅអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ មានសុពលភាពរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្រ លើកលែងតែមានការព្យួរ ឬការដកហូតដោយអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

**ប្រការ១៨ .–**

រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ក្នុងរយៈពេលមិនតិចជាង៣ (បី) ខែ មុនកាលបរិច្ឆេទផុតសុពលភាព តាមការកំណត់នៅក្នុងគំរូសំណុំបែបបទដូចមានក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។ ករណីខកខានក្នុងការស្នើសុំជាថ្មី វិញ្ញាបនបត្រអនុញ្ញាតដំណើរការនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

**ប្រការ១៩ .–**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកំពុងដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ ឬឈើកៅស៊ូ ក្រោមការអនុញ្ញាតណាមួយ ដែលមានសុពលភាពនៅមុនពេលប្រកាសនេះចូលជាធរមាន ត្រូវបំពេញសំណុំបែបបទស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការឡើងវិញ តាមនីតិវិធីនៃប្រកាសនេះ ក្នុងរយៈពេលមិនលើស៦ (ប្រាំមួយ) ខែ នៅអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ២០ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២១ .–**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៦ កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ